# San Diego Unified School District
## Fact Sheet

# ផលប្រយោជន៍នៃការចូលរៀនទៅតាមសាលារៀនទៅក្បែរតំបន់លោកអ្នក

លោកអ្នកអាចធ្វើការជ្រើសរើសសាលារៀនអោយកូនសិក្សាបាន។ ការជ្រើសរើសសាលារៀនអោយកូនរៀនទៅតាមតំបន់របស់លោកអ្នករស់នៅអាចធ្វើអោយមានការងាយស្រួលសំរាប់ការរស់នៅសំរាប់គ្រួសារលោកអ្នក។ ចូរសួរខ្លួនឯងថា " តើខ្ញុំឲ្យតម្លៃនៅដល់កូនរបស់ខ្ញុំសិក្សាបានយ៉ាងណា? " ជាដំបូងលោកអ្នកត្រូវតែធ្វើការជ្រើសរើសសាលារៀនអោយកូនរៀន។ ទាមជាមាតាបិតា ការរួមសហការណ៏ដ៏សកម្មមានន័យថា បណ្តុះបណ្តាលការគាំទ្រទាក់ទងកូនលោកអ្នកសិក្សាអោយមានជ័យជំនះបាន។

នេះជាផលប្រយោជន៍ដែលលោកអ្នកជ្រើសរើសសាលារៀនអោយកូនរៀនទៅតាមសាលារៀនដែលក្បែរតំបន់របស់លោកអ្នករស់នៅ:

- ពេលលោកអ្នករស់នៅក្នុងតំបន់នេះ លោកអ្នកមានសិទ្ធិឲ្យកូនចូលរៀនទៅតាមតំបន់នេះ។ ហើយកូនលោកអ្នកមិនចាំបាចចុះឈ្មោះនៅក្នុងបញ្ជីរងចាំ ព្រមទាំងមិនចាំបាច់មានថ្ងៃខែកំណត់ចុះឈ្មោះកូនចូលរៀនផងដែរ។ កូនលោកអ្នកអាចចុះឈ្មោះបានមុនគេ។
- គ្រួសារសិស្សមានការចូលរួមជាមួយសហគមន៍បានជិតដិត ព្រមទាំងមានអារម្មណ៏ល្អជាមួយសមាជិកសហគមន៍ផងដែរ។
- លោកអ្នកបានបង្កើតការទាក់ទងយ៉ាងខ្លាំងក្លាជាមួយអ្នកដែលរស់នៅក្នុងតំបន់លោកអ្នកបាន។
- លោកអ្នកអាចទៅពិគ្រោះកិច្ចការសាលារៀនឬកិច្ចការទូទៅជាមួយគ្រួសារដែលរស់នៅក្បែរតំបន់របស់លោកអ្នកបានយ៉ាងងាយស្រួល។
- លោកអ្នកនឹងមិនចាំបាច់ចំណាយពេលវេលាច្រើនបើកឡានជូនកូនទៅរៀន។
- លោកអ្នកមានការងាយស្រួលមកចូលរួមបំរើកិច្ចការនៅតាមសាលរៀន ព្រមទាំងមកចូលរួមប្រជុំជាមួយលោកគ្រូ-អ្នកគ្រូបាន។
- កូនលោកអ្នកមានពេលវេលាច្រើនលេងកំសាន្តជាមួយមិត្រភក្រដែលនៅក្បែរផ្ទះ។
- កូនលោកអ្នកអាចទៅរៀនសាលារៀនជាមួយមិត្រភក្រដែលលេងជាមួយ ព្រមទាំងអាចធ្វើកិច្ចការសាលា និងកិច្ចការដែលត្រូវដាក់អោយធ្វើនៅតាមផ្ទះផងដែរ។

ដើម្បីធ្វើការពិនិត្យមើលសាលារៀននៅក្បែរតំបន់លោកអ្នករស់នៅ សូមបើកប្រព័ន website របស់ក្រសួងអប់រំប្រចាំក្រុង: http://www.sandi.net/schoolfinder.

### សង្ខេប

- ❖ រស់នៅក្នុងតំបន់ជាមួយគ្នា ហើយសាលារៀនផ្តល់ការអនុញ្ញាតិអោយលោកអ្នកអាចចុះឈ្មោះកូនចូលរៀនបានមុនគេ។
- ❖ មិនចាំបាច់រង់ចាំក្នុងការចុះឈ្មោះចូលរៀន។
- ❖ មិនចាំបាច់មានថ្ងៃកំណត់ចុះឈ្មោះចូលរៀន។
- ❖ ចូលរួមពិគ្រោះជាមួយសហគមន៍បាន។
- ❖ មានទំនាក់ទំនងខ្លាំងក្លាជាមួយមាតាបិតាដែលរស់នៅក្នុងតំបន់ជាមួយគ្នា។
- ❖ ពិគ្រោះអំពី បញ្ហាសាលារៀនជាមួយមាតាបិតាដែលរស់នៅក្នុងតំបន់ជាមួយគ្នា ប្រសើរជាជាងទូរស័ព្ទ ឬបើកឡានទៅធ្វើការពិគ្រោះដោះស្រាយបញ្ហានៅតាមសាលារៀន។
- ❖ មានពេលវេលាច្រើនជួបជាមួយកូន។
- ❖ កូនលោកអ្នកអាចលេងកំសាន្ត និងធ្វើកិច្ចការដែលត្រូវដាក់ឲ្យធ្វើនៅតាមផ្ទះដូចមិត្រភក្រដែលកូនលោកអ្នកបានលេងជាមួយ។
- ❖ បើកូនរបស់លោកអ្នកមិនបានចូលរៀនសាលារៀននៅក្បែរតំបន់លោកអ្នករស់នៅ តើលោកអ្នកនឹងមានលទ្ធភាពចូលរួមប្រជុំ និងកម្មវិធីទូទៅនៅតាមសាលារៀនរបស់កូនលោកអ្នកឬទេ?
- ❖ វាមានការងាយស្រួលសំរាប់ មាតាបិតាដែលស្នាក់បំរើកិច្ចការដល់សាលារៀន។

នោះជាការធម្មតាក្នុងការជ្រើសរើសសាលារៀនទូទៅអោយកូនចូលរៀន វាជាការសំខាន់ចំពោះលោកអ្នកត្រូវតែត្រូវតែចូលរួមជាមួយកូនលោកអ្នកសិក្សា។ ពេលធ្វើការជ្រើសរើសាលារៀនឲ្យកូនរៀន វាជាការសំខាន់ចំពោះលោកអ្នកធ្វើការពិនិត្យមើលនូវសេចក្តីត្រូវការរបស់កូនលោកអ្នកខាងផ្នែកចុះសម្រុងជាមួយមិត្រភក្រនៅតាមសាលារៀន មានចិត្តធ្វើការសិក្សានៅតាមសាលារៀន។ ជាញឹកញ៉ាប់ កូនលោកអ្នកបង្កើតបញ្ហាច្រើនពេលកូនលោកអ្នកធ្វើការទាក់ទងជាមួយក្មេងៗដែលមិនរៀននៅតាមសាលារៀនជាមួយគ្នា។

មាតាបិតាភាគច្រើនបានរាយការណ៏ថា ការជ្រើសរើសសាលារៀនក្បែរផ្ទះអាចផ្តល់ពេលវេលាបានច្រើនក្នុងការជួបជុំកូននៅតាមសាលារៀន និងនៅផ្ទះ។ លោកអ្នកអាចសម្រេចកិច្ចការល្អៗសំរាប់សាលារៀនបាន។ តើសាលារៀននោះផ្តល់ការសិក្សាដែលមានគុណភាពល្អដល់កូនលោកអ្នកសិក្សាឬទេ? តើសាលារៀននោះផ្តល់គោលការសិក្សាដែលលោកអ្នក និងកូនលោកអ្នកចង់បានឬទេ? ការជ្រើសរើសាលារៀនអោយកូនសិក្សាគឺមិនមានបញ្ហាអ្វីឡើយ វាជាការសំខាន់លោកអ្នកត្រូវធ្វើការចាត់ចែង, ធ្វើការពិនិត្យមើលកិច្ចការកូនសិក្សាឲ្យបានល្អ ហើយលោកគ្រូ-អ្នកគ្រូត្រូវមានគោលការខ្ពស់បង្រៀនសិស្សសិក្សា។